**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...១៤...សសរ...

# សេចក្ដីសម្រេច
## ស្ដីពី
## សប្ដាហ៍ជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០០៥ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក

### ស ម្រេ ច

**ប្រការ ១ .-**

ត្រូវបានកំណត់យកថ្ងៃទី ០៧ ដល់ ថ្ងៃទី ១៤ ខែមេសា ជារៀងរាល់ឆ្នាំ ដើម្បីប្រារព្ធជា សប្ដាហ៍ជាតិសម្រាប់សុវត្ថិភាពចរាចរណ៍ផ្លូវគោក និងដើម្បីចូលរួមសប្ដាហ៍សហប្រជាជាតិស្ដីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក លើសកលលោក ។

**ប្រការ ២ .-**

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវលើកកម្ពស់ការទទួលខុសត្រូវចូលរួម និង ចាត់ចែងរៀបចំឱ្យមានជាសកម្មភាពសាធារណៈនានា ដើម្បីបង្កើនការយល់ដឹង និងចូលរួមចំណែកការពារ ទប់ស្កាត់កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងដើម្បីចូលរួមប្រារព្ធ " **សប្ដាហ៍ជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក** " ឱ្យបានអធិកអធម ។

**ប្រការ ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ត្រូវអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com